ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ:០១៥០/១២ ក.អ.ជ.សវ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម / ០១៩៦ /១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ បក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួល ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសំរេចលេខ ៥៦ សសរ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញអនុក្រឹត្យ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការផ្ទេរទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសេចក្តីសម្រេចលេខ ០១៣៨/១២ក.អ.ជ.ស.វ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការបង្កើតក្រុមការងារវិមជ្ឈការ និងវិសមជ្ឈការប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្សី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

# ស ម្រេ ច

**ប្រការ ១.**_ បង្កើតក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីគាំទ្រសកម្មភាពរបស់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ ដូចមានសមាសភាពខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១. | លោកជំទាវ | **ជាំ ដារីនី** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. | លោក | **សែត សាម៉ន** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | អនុប្រធាន |
| ៣. | លោកស្រី | **ខៀវ មាលតី** | អនុប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ | អនុប្រធាន |
| ៤. | លោកស្រី | **ឡាច សាម៉ន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៥. | លោក | **សែត សាម៉ុន** | អនុប្រធានការិ.ន.ដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |
| ៦. | កញ្ញា | **គង់ សុជាតា** | អនុប្រធានការិ.ន.ដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក និងជាមន្ត្រីរដ្ឋបាល |
| ៧. | លោក | **កែវ ប៊ុនរិទ្ធ** | មន្ត្រី ន.ដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ៨. | លោក | **ឬទ្ធី ឡុងឌី** | មន្ត្រី ន.ដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិក |

**ប្រការ ២.**_ ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងអភិវឌ្ឍន៍ជនបទមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ធ្វើជាលេខាធិការដ្ឋានជូនក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួង
- ជួយរៀបចំផែនការសកម្មភាពរបស់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសលើការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យរបាយការណ៍បញ្ជីវិភាគមុខងារ (Functional Mapping) និងផ្តល់យោបល់ជូនក្រុមការងារវិមជ្ឈការ **និង**វិសហមជ្ឈការ
- ពិនិត្យរបាយការណ៍ស្តីពីការពិនិត្យមុខងារឡើងវិញ(Functional Review) និងផ្តល់យោបល់ជូនក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ
- រៀបចំរបាយការណ៍សម្រាប់កិច្ចប្រជុំនានាពាក់ព័ន្ធ និងកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ធ្វើកំណត់ហេតុអង្គប្រជុំជូនក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ
- រៀបចំរបាយការណ៍ផ្សេងទៀតជូនក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ ដើម្បីពិនិត្យនិងសម្រេច
- ចូលរួមប្រជុំតាមការអញ្ជើញ និងចាត់តាំងរបស់ប្រធានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ
- ធ្វើការទំនាក់ទំនងជាប្រចាំជាមួយលេខាធិការដ្ឋានគ.ជ.អ.ប ពាក់ព័ន្ធនឹងការងារវិមជ្ឈការ និងវិសហមជ្ឈការ
- ជួយសហការ និងសម្របសម្រួល ជាមួយទីប្រឹក្សាជាតិ **និង**អន្តរជាតិ ដែលធ្វើការពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

- សិក្សាស្រាវជ្រាវលើឯកសារពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដូចជាច្បាប់គ្រប់គ្រងអង្គការអនុក្រឹត្យស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (ផអ៣) សេចក្តីណែនាំរបស់ គ.ជ.អ.ប ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ ការពិនិត្យមុខងារឡើងវិញ និងឯកសារបទដ្ឋានគតិយុត្តផ្សេងទៀត
- ការងារផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ

**ប្រការ ៣._** ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៤._** សេចក្តីសម្រេចណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥._** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត គ្រប់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជា សុផារ៉ា

<u>កន្លែងទទួល</u> ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។
- លេខាធិការដ្ឋាន គ.ជ.អ.ប (ដើម្បីជូនជ្រាប)
- ដូចមានចែងក្នុងប្រការ១ និង ៥ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ